# សេចក្តីប្រកាសព័ត៌មានរួម

# ថវិកា ១២,៣លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយសហភាពអឺរ៉ុប ប្រទេសស៊ុយអែដ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សម្រាប់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី២

ភ្នំពេញ-ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ - ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានចូលរួមជាអធិបតីក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការនូវកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (កម្មវិធី CCCA) ដំណាក់កាលទី២។ ថវិកាសរុបប្រមាណ **១២,៣លានដុល្លារអាមេរិក** ត្រូវបានផ្តល់ដោយសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ ចាប់ពីខែកក្កដា ឆ្នាំ២០១៤ រហូតដល់ ខែមិថុនា ឆ្នាំ២០១៩។ កម្មវិធី CCCA ត្រូវបានសម្របសម្រួលដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ហើយក្រសួងបរិស្ថាន (នាយកដ្ឋានប្រែប្រួលអាកាសធាតុ) ជាអ្នកអនុវត្ត។

ថ្លែងក្នុងពិធីបើក ឯកឧត្តម **សាយ សំអាល់** បានមានប្រសាសន៍ថា "CCCA គឺជាកម្មវិធីនាំមុខមួយរបស់ក្រសួងបរិស្ថាន ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០១០ ហើយកំពុងបន្តបំពេញតួនាទីសម្របសម្រួលការងារឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ កម្មវិធី CCCA គឺឧទាហរណ៍ជាក់លាក់មួយរបស់ក្រសួងបរិស្ថានក្នុងការសម្របសម្រួលការងារប្រែប្រួលអាកាសធាតុជាមួយអន្តរក្រសួង ដើម្បីកសាងសមត្ថភាពបណ្តាក្រសួង ស្ថាប័នរដ្ឋ ឆ្ពោះទៅរកការអភិវឌ្ឍដោយចីរភាព"។ ឯកឧត្តមបានបន្តថា "កម្មវិធី CCCA ដំណាក់កាលទី២ នឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យា ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់មូលនិធិសម្រាប់ការងារស្រាវជ្រាវ និងភាពជាដៃគូជាមួយវិស័យអប់រំ"។

ជាមួយគ្នានេះដែរ សហភាពអឺរ៉ុប ប្រទេសស៊ុយអែដ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានបង្ហាញទស្សនៈរួមគ្នាអំពីមោទនភាពក្នុងការបន្តជួយគាំទ្រកម្មវិធី CCCA តាមរយៈពិធីចុះហត្ថលេខានាថ្ងៃនេះ។ ឆ្នាំ២០១៥ គឺជាពេលវេលាសំខាន់ ក្នុងកិច្ចប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុថ្នាក់អន្តរជាតិ តំបន់ និងមូលដ្ឋាន ដោយសារគេរំពឹងថានឹងសម្រេចបាននូវកិច្ចព្រមព្រៀងអាកាសធាតុថ្មីមួយ នៅក្នុងសន្និសីទបណ្តាភាគីលើកទី២១ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងប៉ារីស នៅខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ។ ក្នុងបរិបទនេះ ដៃគូអភិវឌ្ឍន៍នៃកម្មវិធី CCCA បានបន្តប្តេជ្ញាចិត្តរួមគ្នា ដើម្បីគាំទ្រកម្ពុជាក្នុងការពង្រឹងសមត្ថភាពស្ថាប័នសំដៅសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវភាពធន់នឹងអាកាសធាតុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នាចុងឆ្នាំ២០១៤ ប្រទេសស៊ុយអែដ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សម្រាប់កម្មវិធី CCCA ដំណាក់កាលទី២ ដោយប្រទេសស៊ុយអែដបានផ្តល់ថវិកាចូលរួមសរុបប្រមាណ **៣,៨លានដុល្លារអាមេរិក**។ ចំណែកនៅក្នុងពិធីនាថ្ងៃនេះ សហភាពអឺរ៉ុប និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយថវិកាដល់កម្មវិធី CCCA ដំណាក់កាលទី២ ក្នុងនោះសហភាពអឺរ៉ុបបានផ្តល់ថវិកាចូលរួម **៦លានអឺរ៉ូ**។ បន្ទាប់មក ក្រសួងបរិស្ថាន និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានចុះហត្ថលេខាជាផ្លូវការសម្រាប់ការអនុវត្តកម្មវិធី CCCA ដំណាក់កាលទី២ ក្នុងថវិកាសរុប **១២,៣លានដុល្លារអាមេរិក** ដោយរួមបញ្ចូលទាំងថវិកាចូលរួមរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ **១,១៥លានដុល្លារអាមេរិក**។

កម្មវិធី CCCA ដំណាក់កាលទី២ នឹងគាំទ្រចក្ខុវិស័យកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងផ្អែកលើចំណេះដឹងជាគោល ដោយផ្តោតលើអាទិភាពសំខាន់ចំនួន ៣ គឺ៖ ១) ការពង្រឹងអភិបាលកិច្ចការប្រែប្រួលអាកាសធាតុ ២) ការតម្រង់ទិសវិនិយោគនៃវិស័យសាធារណៈ និងឯកជន ទាំងពីប្រភពក្នុងប្រទេស និងក្រៅប្រទេស ឆ្ពោះទៅរកការវិនិយោគដែលឆ្លាតវៃផ្នែកអាកាសធាតុ; និង ៣) ការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យាសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

អញ្ជើញចូលរួមនៅក្នុងអង្គពិធីនេះរួមមាន សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ មន្ត្រីក្រសួងបរិស្ថាន និងតំណាងដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជាសហភាពអឺរ៉ុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងស្ថានទូតស៊ុយអែដ។

*កំណត់សម្គាល់សម្រាប់អ្នកសារព័ត៌មាន៖*

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី១ គឺជាអភិក្រមទូលំទូលាយ និងច្នៃប្រឌិតថ្មីដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលបានចាប់ផ្តើមអនុវត្តពីឆ្នាំ២០១០ ដល់២០១៤ ដោយបានសម្រេចសមិទ្ធផលធំៗជាច្រើន រួមមាន ការរៀបចំផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ និងផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពរបស់ក្រសួងស្ថាប័នចំនួន ៩ ការអនុវត្តដោយជោគជ័យនូវគម្រោងសាកល្បងបន្សាំនឹងការប្រែប្រួលអាកាសធាតុ សរុបចំនួន ២០ (អនុវត្តដោយស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល) និងការបង្កើនទំនាក់ទំនង និងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈឯកសារចំណេះដឹង និងពិធីនានា។ កម្មវិធី CCCA ដំណាក់កាលទី១ បានទទួលថវិកាគាំទ្រពីសហភាពអឺរ៉ុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក (DANIDA) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ សរុបចំនួន **១០,៨ លានដុល្លារអាមេរិក**។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


- ក្រសួងបរិស្ថាន៖ ឯកឧត្តម សៅ សុភាព នាយកខុទ្ទកាល័យ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន
  012 971 222, saosopheap@yahoo.com
- សហភាពអឺរ៉ុប (EU)៖ លោកស្រី ពូន ប៉ុក មន្ត្រីព័ត៌មាន
  012 347716, Pok.POUN@eeas.europa.eu
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)៖ លោក កែ មុនធិត ផ្នែកទំនាក់ទំនង,
  015 589 839, munthit.ker@undp.org
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (SIDA)៖ លោកស្រី Kristina Kühnel,
  016 881 498, Kristina.kuhnel@gov.se

# Joint Press Release

## 12.3 Million US$ committed by EU, Sweden and UNDP for the second phase of the Cambodia Climate Change Alliance

**PHNOM PENH, 12 March 2015:** Minister of Environment, **H.E. Say Samal**, who is also the Chair of the National Climate Change Committee, presided over the official launch ceremony for the Cambodia Climate Change Alliance (CCCA) Phase II. A total of **12.3 Million US$** have been allocated to the programme from the European Union (EU), Swedish International Development Agency (SIDA) and United Nations Development Programme (UNDP) to support the implementation of the Cambodia Climate Change Strategic Plan 2014-2023 for the period from July 2014 to June 2019. The programme is administered by UNDP, with the Ministry of Environment through Climate Change Department as implementing agency.

In his welcome remarks, **H.E. Say Samal** stated "The CCCA has been the flagship programme for the Ministry of Environment since 2010, and continues to play a coordinating role in our response to climate change. CCCA is a concrete example of the inter-ministerial body coordinated by Ministry of Environment to build capacity towards sustainable development across Government ministries and agencies." He further added "the programme will also put a strong focus on the development of human resources and technologies required for climate change response, through grants for research and partnerships with the education sector."

The EU, Sida and UNDP are proud to formalize today their continued support to the CCCA. The year of 2015 is a crucial time for the fight against climate change at global, regional and local levels, due to the fact that a new climate agreement is expected in the 21st Conference of the Parties meeting of the United Nations Framework Convention on Climate Change scheduled to take place in Paris in December 2015. In this context, CCCA development partners confirm their joint commitment to support Cambodia in strengthening its institutional capacity to better coordinate effective climate change responses and to ensure strengthened resilience at both national and sub-national levels.

Sweden and UNDP, end of last year, signed an agreement for CCCA Phase II in which Sweden contribution of **3.8 million US$**. During today's official launch ceremony, the EU and UNDP signed a funding agreement for CCCA, for EU contribution of **6 million Euros**. Then, the Ministry of Environment and UNDP officially signed an agreement for CCCA Phase II with a total budget of **12.3 million US$**, including **1.15 million US$** from UNDP itself.

The programme will support the vision of a green, low-carbon, climate-resilient, equitable, sustainable and knowledge-based society for Cambodia, with three main drivers focusing on: 1)

Strengthening the governance of climate change; 2) Orienting public and private, domestic and external resources towards climate-smart investments; and 3) Developing human and technological capital for climate change response.

The ceremony was attended by members of National Climate Change Committee, MoE officials, and representatives of development partners, including EU, UNDP, and Swedish Embassy.

***Note to Editor:***

The Cambodia Climate Change Alliance (CCCA) Phase I is a comprehensive and innovative approach to address climate change in Cambodia that had been active from 2010-2014 with significant results including the development of the Cambodia Climate Change Strategic Plan 2014-2023 and the corresponding strategic plans and actions plans in nine priority ministries and agencies, the successful operation of a grant facility (20 Government and NGO pilot projects supported in all areas of the climate change response), and increased visibility and knowledge of climate change, through knowledge products and advocacy events. The phase I of CCCA, was supported by EU, UNDP, DANIDA and SIDA with total budget of 10.8 million US$.

**For further information, please contact:**


- Ministry of Environment: **H.E. Sao Sopheap,** spokesperson, 012 971 222, saosopheap@yahoo.com
- EU: Ms. Poun Pok, Press and Information Officer, 012 347716, Pok.POUN@eeas.europa.eu
- UNDP: Mr. Ker Munthit, Chief of Communications, 015 589 839, munthit.ker@undp.org
- SIDA: Ms. Kristina Kühnel, Head of Development Cooperation Section; 016 881 498, Kristina.kuhnel@gov.se